ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ១២០៥ សរ.សជណ

ថ្ងៃ.................ខែ.................ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៨

## ជម្រាបជូន
## ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ** ៖ ស្តីពីការរៀបចំដាក់ឱ្យដំណើរការអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តសម្រាប់ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**យោង** ៖- អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- ប្រកាសលេខ៣៨៧១ ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្ត ជ្រាបថា មកដល់ពេលនេះ ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា រដ្ឋបាលរាជធានី ខេត្តភាគច្រើនបានរៀបចំទីកន្លែង បំពាក់សម្ភារ និងឧបករណ៍ចាំបាច់នានារួចរាល់ហើយសម្រាប់ការដាក់ឱ្យដំណើរការអង្គភាពច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ។ ជាមួយគ្នានេះ ក្រសួងមហាផ្ទៃក៏បានដាក់ចេញនូវសៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយ ព្រមទាំងបានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនៃអង្គភាពច្រកចេញចូលតែមួយគ្រប់រដ្ឋបាលរាជធានី ខេត្តរួចហើយផងដែរ។ អាស្រ័យហេតុនេះ ក្រសួងមហាផ្ទៃស្នើរដ្ឋបាលរាជធានី ខេត្តត្រូវដាក់ឱ្យដំណើរការអង្គភាពច្រកចេញចូលតែមួយឱ្យបាននៅក្នុងសប្តាហ៍ទី៣នៃខែកក្កដា ឆ្នាំ២០១៨នេះ។

ដើម្បីធានាដល់ការចាប់ផ្តើមដំណើរការអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តឱ្យបានឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់គ្រប់រដ្ឋបាលរាជធានី ខេត្ត អនុវត្តនូវកិច្ចការចាំបាច់មួយចំនួនដូចខាងក្រោម៖

- រដ្ឋបាលរាជធានី ខេត្តដែលមិនទាន់បានរៀបចំទីកន្លែង និងបំពាក់សម្ភារសម្រាប់ដំណើរការអង្គភាពច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋត្រូវពន្លឿនការរៀបចំឱ្យបានរួចរាល់នៅដើមខែកក្កដា ឆ្នាំ២០១៨នេះ
- រដ្ឋបាលរាជធានី ខេត្តត្រូវជម្រុញ និងដាក់ចេញនូវសេចក្តីសម្រេចស្តីពីការកំណត់ប្រភេទសេវា និងក្របខណ្ឌពេលវេលាដាក់លាក់ ដែលត្រូវផ្តល់យោបល់បច្ចេកទេសដោយមន្ត្រីដែលបានចាត់តាំងឱ្យមកបំពេញការងារនៅផ្នែកជួរក្រោយនៃអង្គភាពច្រកចេញចូលតែមួយ ព្រមទាំងប្រភេទសេវា និងក្របខណ្ឌពេលវេលាដែលត្រូវផ្តល់យោបល់បច្ចេកទេសនៅមន្ទីរជំនាញឱ្យបានរួចរាល់នៅដើមខែកក្កដា ឆ្នាំ២០១៨

- អភិបាលរាជធានី ខេត្តត្រូវរៀបចំដឹកនាំកិច្ចប្រជុំជាមួយមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធដើម្បី៖
  - ✓ កំណត់ថ្ងៃជាក់លាក់ក្នុងសប្តាហ៍ទី៣នៃខែកក្កដា ឆ្នាំ២០១៨ ដើម្បីចាប់ផ្តើមដំណើរការអង្គភាពច្រកចេញចូលតែមួយ
  - ✓ ណែនាំដល់មន្ទីរ អង្គភាពពាក់ព័ន្ធត្រូវបញ្ឈប់ការទទួលពាក្យស្នើសុំសេវារដ្ឋបាល និងត្រូវផ្ទេរកិច្ចការនេះទៅអង្គភាពច្រកចេញចូលតែមួយត្រឹមថ្ងៃដែលបានឯកភាពគ្នានៃការចាប់ផ្តើមដំណើរការអង្គភាពច្រកចេញចូលតែមួយ
  - ✓ ណែនាំដល់មន្ទីរ អង្គភាពពាក់ព័ន្ធត្រូវបន្តពិនិត្យ និងសម្រេចលើពាក្យស្នើសុំសេវារដ្ឋបាលនានាដែលមន្ទីរ អង្គភាពបានទទួលមុនថ្ងៃនៃការចាប់ផ្តើមដំណើរការអង្គភាពច្រកចេញចូលតែមួយ
  - ✓ ពិភាក្សាជាមួយមន្ទីរ អង្គភាពនានាដើម្បីពិនិត្យ កែសម្រួលនូវទម្រង់នៃលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណដែលធ្លាប់ចេញដោយមន្ទីរ អង្គភាពឱ្យទៅជាលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណដែលត្រូវចេញដោយរដ្ឋបាលរាជធានី ខេត្ត
  - ✓ ពិភាក្សាជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធលើកិច្ចការចាំបាច់ផ្សេងទៀតដែលត្រូវរៀបចំ និងដោះស្រាយ ពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ស្របតាមលិខិតបទដ្ឋានជាធរមាន។
- អភិបាលរាជធានី ខេត្តត្រូវដឹកនាំ សម្របសម្រួល គាំទ្រ និងតាមដានត្រួតពិនិត្យការអនុវត្តការងាររបស់អង្គភាពច្រកចេញចូលតែមួយជាប្រចាំ ដើម្បីឱ្យអង្គភាពនេះអាចដំណើរការបានដោយរលូន និងមានប្រសិទ្ធភាពខ្ពស់
- រដ្ឋបាលរាជធានី ខេត្តត្រូវរៀបចំការយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយ និងធ្វើការផ្សព្វផ្សាយតាមមធ្យោបាយនានាដែលមានក្នុងរាជធានី ខេត្ត អំពីការដាក់ឱ្យដំណើរការផ្តល់សេវារដ្ឋបាលតាមអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត
- រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវរៀបចំឱ្យមានការទទួល និងការរក្សាទុកចំណូលដែលទទួលបានពីការបង់កម្រៃសេវាតាមអង្គភាពច្រកចេញចូលតែមួយឱ្យបានគត់មត់។ ទន្ទឹមនេះក្រសួងមហាផ្ទៃនឹងសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំ និងដាក់ចេញនូវបែបបទ នីតិវិធីសម្រាប់ការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់ចំណូលទាំងនេះក្នុងពេលឆាប់ៗខាងមុខ
- រដ្ឋបាលរាជធានី ខេត្តត្រូវធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនៃការអនុវត្តកិច្ចការខាងលើនេះ មកក្រសួងមហាផ្ទៃ ដើម្បីគាំទ្រ និងតាមដានការអនុវត្តកិច្ចការទាំងនេះ។

ក្រសួងមហាផ្ទៃនឹងរៀបចំពិធីសម្ពោធ និងដាក់ឱ្យដំណើរការជាផ្លូវការរបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តនៅទូទាំងប្រទេសនៅពេលក្រោយ។

ចៅ

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវអភិបាលមេត្តាពិនិត្យ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម លោកជំទាវទទួលនូវការរាប់អានអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

ចម្លងជូន៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ